ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៣

នៅក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារនីតិកម្ម

-បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០២២ និងគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣

-បានប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងឆ្លងឯកសារស្តីពី លទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

### ២- មុខងារតាមដានការអនុវត្តច្បាប់

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងសហការី ដើម្បីឈ្វេងយល់ពីការវិវឌ្ឍការងារ បញ្ហាប្រឈម និងចក្ខុវិស័យរាជបណ្ឌិត្យសភាកម្ពុជា នៅសាលប្រជុំរាជបណ្ឌិត្យសភាកម្ពុជា រាជធានីភ្នំពេញ

+អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្ត មន្ទីរព័ត៌មាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែន ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនបរទេស ការផ្តល់ប័ណ្ណការងារ ការត្រួតពិនិត្យប័ណ្ណ ឬសៀវភៅការងាររបស់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

ជនបរទេសដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន បញ្ញាប្រឈម សំណូមពរនានា នៅខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

**៣-មុខងារតំណាង**

-**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានចាត់ឱ្យលោកជំទាវ **សាយ ចាន់ណាក់** ជាតំណាងដ៏ខ្ពង់ខ្ពស់ អញ្ជើញនាំយកថវិការបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវះ

+ចូលរួមព្រះរាជពិធីចម្រើនអាយុវឌ្ឍនមង្គល ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី-កិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះជន្មាយុ៩២ ឈានចូល៩៣ព្រះវស្សា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ

+ចូលរួមបុណ្យសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ស៊ុយ ស៊ុំម៉ាឡៃ** ត្រូវជាម្តាយបង្កើតរបស់លោកជំទាវ **ពុំ ចន្ទីនី** និងសពឧបាសិកា **លាត នាង** ត្រូវជាម្តាយក្មេករបស់លោកឧកញ៉ា **អ៊ឹង ឆៃវួន** អគ្គនាយកទូរទស្សន៍ និងវិទ្យុហង្សមាស

+ចុះសួរសុខទុក្ខ និងនាំយកថវិកាសម្តេចប្រធានព្រឹទ្ធសភា ឧបត្ថម្ភថ្លៃព្យាបាលជំងឺលោកស្រី **ម៉ែត គឹមឡាយ** ដែលសម្រាកព្យាបាល នៅគ្លីនិកព្យាបាលជំងឺបេះដូងពិភពថ្មី រាជធានីភ្នំពេញ

-បានរៀបចំចាត់ចែងជូន**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភាះ

+អញ្ជើញទស្សនាការហាត់សមរបាំ ដើម្បីត្រៀមសម្តែងក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា នៅនាយកដ្ឋានសិល្បៈទស្សនីយភាព នៃក្រសួងវប្បធម៌ និងវិចិត្រ-សិល្បៈ រាជធានីភ្នំពេញ

+អញ្ជើញក្រុងពាលីសុំសេចក្តីសុខ និងចូលរួមជាគណៈអធិបតីក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា នៅទីក្រុងកោះពេជ្រ រាជធានីភ្នំពេញ

-បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរះ

+លោកជំទាវកិត្តិនីតិកោសលបណ្ឌិតប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងប្រគល់ថ្នាំពេទ្យ បរិក្ខារពេទ្យ ឧបករណ៍តេស្តរហ័ស និងថវិកាមួយចំនួនជូនអាជ្ញាធរខេត្តកណ្តាល

+ឯកឧត្តមអនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចូលរួមប្រជុំ ដើម្បីពិនិត្យបញ្ជាក់តួលេខស្ថិតិប្រជាពលរដ្ឋ មានប័ណ្ណសមធម៌កម្រិតក្រ១ កម្រិតក្រ២ និងពលរដ្ឋងាយរងហានិភ័យអំឡុងពេលមានសម្ពាធអតិផរណា នៅរាជធានីភ្នំពេញ

+ឯកឧត្តមលេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយជូនលោកតា លោកយាយជួបការលំបាកចំនួន១៧០គ្រួសារ នៅសង្កាត់ព្រះពន្លា

ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតជ័យលាភី ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** ប្រធានគណៈកម្មាធិការអាហារូបករណ៍សិស្ស និស្សិតក្រីក្រ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសេដ្ឋកិច្ច (UME)

+លោកជំទាវប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ក្របខណ្ឌគណនេយ្យភាព ជាពហុវិស័យសម្រាប់ឆ្លើយតបនឹងជំងឺរបេង នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

+ឯកឧត្តមសមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីបើកការប្រកួតបាល់ទាត់ពានរង្វាន់សមាគមរាជសីហ៍ខេត្តកំពត លើកទី១ នៅពហុកីឡដ្ឋានខេត្តកំពត

+ឯកឧត្តមប្រធានគណៈកម្មាទី១០ព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ចែកជូនដល់ក្រុមប្រឹក្សាឃុំ និងបងប្អូនប្រជាពលរដ្ឋចំនួន៣០៣នាក់ នៅសាលាឃុំត្រពាំងវែង និងអញ្ជើញជាកិត្តិយសក្នុងពិធីកាត់ឫសសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានា នៅវត្តវិហារ-បិទមាសទិសឧត្តរ ខេត្តកណ្តាល

+សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំវេទិកាជាមួយក្រុមប្រឹក្សាសង្កាត់ ស្តីពីការអភិវឌ្ឍមូលដ្ឋាន និងបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ជានាបានសុខសន្តិភាពចំនួន៥ខណ្ឌ (ខណ្ឌដង្កោ ខណ្ឌកំបូល ខណ្ឌពោធិ៍សែនជ័យ ខណ្ឌសែនសុខ និងខណ្ឌព្រែកព្នៅ) នៅខណ្ឌសែនសុខ

+សមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផ្លូវលេខ១៤៦បេ (វិថីសម្តេចសង្ឃរាជ ទេព វង្ស), ផ្លូវលេខ១៤៨ (តីរវិថីសម្តេចតេជោហ៊ុន សែន), ពិធីបើកការដ្ឋានស្តារ លើកម្រិតគុណភាពផ្លូវជាតិលេខ៣១ លេខ៣៣ និងលេខ៤១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ

+សមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល និងនាំយកឧបករណ៍តេស្តរហ័សជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ប្រគល់ជូនមន្ទីរពេទ្យបង្អែក និងប៉ុស្តិ៍សុខភាពមួយចំនួន នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង

+សមាជិកព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាលថ្មី ឆ្នាំសិក្សា២០២២-២០២៣ និងសំណេះសំណាលជាមួយសិស្សជ័យលាភីប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០២១-២០២២ នៅតាមបណ្តាភូមិភាគនានា

+សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសបានចែកថ្នាំពេទ្យ បរិក្ខារពេទ្យ និងឧបករណ៍តេស្តរហ័សជូនមណ្ឌលសុខភាព នៅតាមបណ្តាខេត្ត ក្រុងនានាចំនួន១២៥លើក និងបានចូលរួមពិធីផ្សេងៗចំនួន៦៤លើក

-បានរៀបចំជូនសមាជិកព្រឹទ្ធសភា និងក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ នៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តបាត់ដំបង

-ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងវត្តល្វាក្រោម សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៣៨នាក់

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែមករា ឆ្នាំ២០២៣ ចំនួន៨០០ក្បាល

-បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា៖

+ក្នុងឱកាសខួប៤៧ឆ្នាំ នៃចំណងអាពាហ៍ពិពាហ៍

+ក្នុងឱកាសខួបទី៣៨ឆ្នាំ នៃការចូលកាន់តំណែងជាផ្លូវការជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

+ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា (ឆ្នាំ១៩៧៩-២០២៣)

-បានរៀបចំសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន០៩លិខិត

-បានរៀបចំ និងផ្ញើសាររំលែកទុក្ខក្នុងនាមថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦លិខិត និងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធរបស់ឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន០២លើក

-បានទទួលពាក្យបណ្តឹងចំនួន០៧ករណី បញ្ជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី កំពុងពិនិត្យសិក្សាចំនួន១១ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-បានរៀបចំចាត់ចែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងជម្រាបលាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកអគ្គរាជទូតតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជាចំនួន០៨រូប ប្រចាំនៅប្រទេសជាមិត្ត

-បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនសមាជិក សមាជិកាព្រឹទ្ធសភា ជាមួយឯកឧត្តម Damien Regnard សមាជិកព្រឹទ្ធសភាបារាំងតំណាងឱ្យប្រជាពលរដ្ឋបារាំងនៅបរទេស, លោកស្រី Jimin Jeong ប្រធានគ្រប់គ្រង G Foundation នៃអង្គការចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ និងថ្នាក់ដឹកនាំនៃក្រុមហ៊ុនផាប៉ាហ្គន និងសាកលវិទ្យាល័យអន្តរជាតិផាប៉ាហ្គន

-បានរៀបចំ សម្របសម្រួលបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភាអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា រួមមាន៖ អញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតលើកទី១៣ របស់សភាតំបន់អាស៊ី(APA) នៅសាធារណរដ្ឋតួកគី, ចូលរួមកិច្ចប្រជុំក្រុមមិត្តភាពនៃសភាទាំងពីរ (កម្ពុជា-វៀតណាម) នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បាន៖

+អនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍របស់រាជរដ្ឋាភិបាលនៃប្រទេសនូវែលសេឡង់ចំនួន១៥នាក់ ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍

+អនុញ្ញាតឱ្យលោក Cedric Gouth អនុប្រធានតំបន់ (l'Eurometropole) ទទួលបន្ទុកការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងទេសចរណ៍នៃសាធារណរដ្ឋបារាំង និងលោកស្រី Sirpen Panprom នាយកទីផ្សារ

នៃមន្ទីរពេទ្យ Phya Thai និងជាតំណាងមន្ទីរពេទ្យនៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

+អញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខារវាងមជ្ឈមណ្ឌលសភាអាស៊ី(PCAsia) ជាមួយលេខាធិការដ្ឋានអន្តរសភាអាស៊ាន (AIPAsecretariat)

–បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ស្ថានទូតវៀតណាម, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការតម្លាភាពកម្ពុជា(TI Cambodia),មូលនិធិសន្តិភាពដើម្បីអភិវឌ្ឍ,រាជបណ្ឌិត្យសភាកម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ (USTH),សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ(RMIT), មជ្ឈមណ្ឌលសភាអាស៊ី(PCAsia), វិទ្យាស្ថានវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថាន Proseth, វិទ្យាស្ថាន Sunrise, វិទ្យាស្ថានSalaCyber, វិទ្យាស្ថានជាតិស្ថិតិ(NIS), ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រថៃឡង់ដ៍(TICA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន និងក្រសួង ស្ថាប័ន បណ្ណាល័យនានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

–បានសហការ និងសម្របសម្រួលជាមួយក្រុមគ្រូពេទ្យមកពីមន្ទីរពេទ្យកាល់ម៉ែតចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី៦ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ,ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារប្រកបដោយជោគជ័យ

–បានចូលរួមប្រជុំកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០៣លើក

–បានប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យ និងស្តាប់របាយការណ៍ស្តីពី ប្រតិបត្តិការចរន្តសាច់ប្រាក់ប្រចាំឆ្នាំ២០២២ របស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ និងអង្គភាពគ្រប់គ្រងមូលនិធិសង្គមកិច្ចមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានប្រជុំពិនិត្យ ពិភាក្សា និងរៀបចំកែប្រែ និងដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការនៃស្ថាប័ននីតិបញ្ញត្តិ

–បានចូលរួមប្រជុំគណៈកម្មការគ្រឿងឥស្សរិយយសសម្រាប់បំពាក់ជូនសមាជិកព្រឹទ្ធសភានីតិកាលទី២

-បានប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចស្តីពី គោលការណ៍ផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាដែលមានស្នាដៃឆ្នើម

-បានប្រជុំត្រួតពិនិត្យអំពីការរៀបចំ (Mobile Application) របស់ព្រឹទ្ធសភា

-បានប្រជុំត្រួតពិនិត្យពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

-បានរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ និងការបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បានរៀបចំផែនការសកម្មភាពដំណាក់កាលទី៤(MAP4) ឆ្នាំ២០២៣ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បានបើកប្រាក់បៀវត្សប្រចាំខែមករា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-បានរៀបចំតារាងប្រាក់បៀវត្សប្រចាំឆ្នាំ២០២៣ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣៦៧លើក

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន១០៨សំណើ

-បានថតចម្លងឯកសារចំនួន៣,៧៥២ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៦៩ក្បាល អស់ក្រដាសសរុបចំនួន២៥,៣១១សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៣៦៧លើក ស្មើនឹង៣,៥២០នាក់

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៤៣លើក

-បានទទួលលិខិតចូលចំនួន៣៩៣ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៣២ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤២ច្បាប់ ស្មើនឹង១៣១នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៧ច្បាប់ ស្មើនឹង០៧នាក់

-បានចុះសួរសុខទុក្ខមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺ ជួបគ្រោះថ្នាក់ចរាចរណ៍ និងលំហែមាតុភាពចំនួន០៤នាក់

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបែងចែកប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភាឆ្នាំ២០២៣ ចំនួន៣,០៩៧សន្លឹក

-បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន១០លើក

-បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-បានទទួលលិខិតសុំអនុញ្ញាតច្បាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកត់ត្រាចូលក្នុងសៀវភៅការងារចំនួន៨០ច្បាប់

-បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៥៧ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន៤៨ប័ណ្ណ

-បានចែកប័ណ្ណ (ប.ស.ស) សម្រាប់ឆ្នាំ២០២៣ ចំនួន៧១ប័ណ្ណ

-បានធ្វើសេចក្តីព្រាងបញ្ជីរាយនាមមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាដែលត្រូវពិនិត្យវាយតម្លៃតម្លើងថ្នាក់បៀវត្សប្រចាំឆ្នាំ២០២៣ ចំនួន០១ច្បាប់

-បានទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យ និងវិទ្យាស្ថាននានាចំនួន០៥កន្លែង

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៥វគ្គ មានសិក្ខាកាមចូលរួមចំនួន៦៧នាក់ និងក្រៅប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន០៣នាក់ ព្រមទាំងសិក្ខាសាលាក្នុងប្រទេសចំនួន០២លើក មានសិក្ខាកាមចូលរួមចំនួន១០៣នាក់

-បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូកូរ៉េ, គណៈប្រតិភូបារាំង និងនិស្សិតជ័យលាភីអាហារូបករណ៍នូវែលសេឡង់ នៅព្រឹទ្ធសភាចំនួន០៣លើក

-បានរៀបចំជួសជុលបន្ទប់ក្រោមអគារក្រហមនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបំពាក់សម្ភារ និងជួសជុលកែលម្អ ហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក, ត្រួតពិនិត្យដំណើរយន្ត សត្វកណ្ដៀរ, រៀបចំ និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, ប្រមូលសម្ភារខូច, បិទលេខកូដសម្ភារសារពើភ័ណ្ឌ, ប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភាចំនួន២០៧គ្រឿង/លើក

-បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៣៨លើក

-បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមករា ឆ្នាំ២០២៣ ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្ដីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមករា ឆ្នាំ២០២៣ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា

-បានការពារសន្ដិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្ដិសុខផ្ទៃក្នុងចំនួន០៨លើក។

**៤.២-ការងារសេវាច្បាប់៖**

-បានទទួលសេចក្ដីព្រាងច្បាប់ចំនួន០២ច្បាប់ ពីរាជរដ្ឋាភិបាល

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្ដីជូនដំណឹង និងលិខិតផ្សេងៗចំនួន៣៣៥ច្បាប់

-បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៧ច្បាប់

-បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

**៤.៣-ការងារស្រាវជ្រាវ៖**

–បានសិក្សាស្រាវជ្រាវលើសេចក្ដីព្រាងច្បាប់បឋមស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈ-កម្មាធិការជាតិសិទ្ធិមនុស្ស ជូនគណៈកម្មការទី១ព្រឹទ្ធសភា

–បានសិក្សាស្រាវជ្រាវ និងចងក្រងឯកសារលើប្រធានបទចំនួន១១ប្រធានបទ

–បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥)

–បានផលិត និងផ្សព្វផ្សាយអត្ថបទស្រាវជ្រាវស្ដីពី កាលានុវត្ត និងបញ្ហាប្រឈមនៃវិស័យវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២

–បានផលិតទិន្នន័យតាមវិស័យរបស់គណៈកម្មការជំនាញទាំង១០ចំនួន៤៨ច្បាប់

–បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រស្ដីពី ស្ថានភាពសេដ្ឋកិច្ច និងបំណុលចំនួន០១ច្បាប់

–បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៧៣អត្ថបទ

–បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមករា ឆ្នាំ២០២៣ ចំនួន០២ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

–បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

–បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលកុំព្យូទ័រ និងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៨៨គ្រឿង/លើក។ បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន១៦៣ប្រធានបទ

–បានរៀបចំបំពាក់កុំព្យូទ័រយួរដៃ ម៉ាស៊ីនPrinter និងម៉ាស៊ីនScannerចំនួន០៩គ្រឿង

–កំពុងបន្តរៀបចំកម្មវិធីទូរសព្ទ (Mobile Application) សម្រាប់គាំទ្រទៅលើការផ្សព្វផ្សាយពីដំណើរការ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជន

–បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១២៥ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅ បញ្ចូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្នី និងសងសៀវភៅចំនួន១៧៨ក្បាល

–បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្ដីពី សកម្មភាព និងលទ្ធផលការងារព្រឹទ្ធសភាចំនួន០២លើក

–បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន

២៨១លើក

-បានសហការត្រួតពិនិត្យលើប្រព័ន្ធដំណើរការប្រព័ន្ធសន្និសីទប្រជុំពីចម្ងាយ កាមេរ៉ា ទូរទស្សន៍ End-Point, ខ្សែHDMI ខ្សែសម្លេង និងប្រព័ន្ធភ្ជាប់មកកាន់ព្រឹទ្ធសភា

-បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Channel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន២,៤៥៣ប្រធានបទ

-បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៥៨លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៩លើក

-បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពនៅមុខអគារក្រហម និងខ្លោងទ្វារធំព្រឹទ្ធសភាចំនួន ១៤លើក

-បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿនល្អ និងរលូនៗ

**៥.៥-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

-បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន០៧លើក

-បានរៀបចំ និងបញ្ជូនសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់នៃបណ្តាប្រទេសជាមិត្ត ថ្នាក់ដឹកនាំអង្គការអន្តរសភា និងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជាចំនួន១០៤លិខិត

-បានបកប្រែឯកសារនានាចំនួន០៦ច្បាប់

-បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៧ច្បាប់

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមករា ឆ្នាំ២០២៣ ចំនួន ០១ច្បាប់

-បានធ្វើហ្វុងអក្សរតុបតែងលម្អស្លាប័នក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករាៗ

**៥.៦-ការងារអគ្គាធិការដ្ឋាន៖**

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៣ ចំនួន១៩លើក

-បានប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន៣៨លើក ប្រចាំសប្តាហ៍ចំនួន០៤លើក និងប្រចាំខែមករា ឆ្នាំ២០២៣

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមករា ឆ្នាំ២០២៣។

## II-ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៣

-ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ ជំងឺកូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ

-បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេក-វិទ្យាព័ត៌មាន

-ធានាប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា។

### ១- មុខងារនីតិកម្ម

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញនីតិកាលទី២ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

២-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងទឹកស្អាត

៣-សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

**២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

*-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ក្នុងរយៈពេលវិស្សមកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣។*

**៣- មុខងារតំណាង**

*-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចូលរួមពិធីសាសនា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា*

*-ត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងទិសដៅការងារ ឆ្នាំ២០២៣ (ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣)*

*-ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញ៖*

*+ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាសង្កាត់ចំនួន៥ខណ្ឌ (ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ និងខណ្ឌជ្រោយចង្វារ) ស្តីពី ការអភិវឌ្ឍមូលដ្ឋានសង្កាត់ ខណ្ឌ ការងារភូមិ សង្កាត់ មានប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ (ថ្ងៃទី០១-០៧ ខែកុម្ភៈ ឆ្នាំ២០២៣)*

*+ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាសង្កាត់ចំនួន៥ខណ្ឌ ស្តីពី ការអភិវឌ្ឍមូលដ្ឋានសង្កាត់ ខណ្ឌ ការងារភូមិ សង្កាត់ មានប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ នៅខណ្ឌមានជ័យ (ថ្ងៃទី២០-២៤ ខែកុម្ភៈ ឆ្នាំ២០២៣)*

*+រៀបចំវេទិកាជាមួយក្រុមប្រឹក្សាសង្កាត់ស្តីពី ការអភិវឌ្ឍមូលដ្ឋាន និងបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាពចំនួន៥ខណ្ឌ (ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ និងខណ្ឌជ្រោយចង្វារ)។*

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

*-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអគ្គទូតនានា នៃប្រទេសជាមិត្ត*

*-ត្រៀមរៀបចំចាត់ចែង និងផ្តល់សេវាជូន***សម្តេចវិបុលសេនាភក្តី សាយ ឈុំ** *ប្រធានព្រឹទ្ធសភា៖*

*+ក្នុងពិធីទទួលសារតាំងជាមួយឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃព្រះរាជាណាចក្រជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា*

*+ក្នុងពិធីជំនួបសម្តែងការគួរសមជាមួយឯកអគ្គរាជទូតនៃព្រះរាជាណាចក្រថៃឡង់ដ៍*

-ត្រៀមទទួលដំណើរទស្សនកិច្ចៈ

+គណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

+គណៈប្រតិភូអគ្គលេខាធិការសភាថៃ

+គណៈកម្មការគោលនយោបាយសង្គមកិច្ចរបស់ព្រឹទ្ធសភា នៃសាធារណរដ្ឋឆែក (សប្តាហ៍ទី៤ ខែកុម្ភៈ ឆ្នាំ២០២៣)

-ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញៈ

+បំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

+ចូលរួមប្រជុំមហាសន្និបាតសហភាពអន្តរសភា(IPU)នៅប្រទេសបារ៉ែន

+ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសភាអាស៊ី(PCAsia)

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCAsia) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត(PCA, AVI) និងដៃគូផ្សេងៗទៀត។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមធ្វើរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៩ និងលើកទី១០ នីតិកាលទី៤

-គ្រប់អង្គភាពពាក់ព័ន្ធត្រៀមធ្វើរបាយការណ៍តាមវិស័យ និងរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំឱ្យបានល្អ និងទាន់ពេលវេលា

-ត្រៀមរៀបចំគម្រោងថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២៤

-ត្រៀមប្រជុំគណៈកម្មការលទ្ធកម្មនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរៀបចំបើកឯកសារដេញថ្លៃឆ្នាំ២០២៣

-ត្រៀមប្រជុំគណៈកម្មការបេឡាសោធននិវត្តន៍ ដើម្បីពិនិត្យកែសម្រួល និងបច្ចុប្បន្នភាព

ប្រាក់សោធននិវត្តន៍ ឱ្យមានសមធម៌ និងយុត្តិធម៌

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែកុម្ភៈឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឱ្យបានទាន់ពេលវេលា

-បន្តវិចារណកម្មថវិកាៈ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុតៈ

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងប្លាស្ទិក)

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ច របស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំការងារកែសម្រួលឋានន្តរសក្តិ និងការតែងតាំងមុខតំណែង

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីៗ ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែងចំនួន០៣គឺៈ

១-គោលការណ៍ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម

២-គោលការណ៍ស្តីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ

៣-គោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្ស

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ធ្វើសម្រង់តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការប្រចាំឆ្នាំ២០២៣

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីៈ វគ្គសេដ្ឋកិច្ច ឌីជីថល, វគ្គវិភាគសារពើភ័ណ្ឌ, វគ្គAdvanced English Language and Communication Skill នៅមជ្ឈមណ្ឌលICON និងវគ្គSpecialized Training Program me on Select WTO Issues Agriculture Services TRIPS and RTAS នៅប្រទេសឥណ្ឌា

-បន្តតាមដានជាមួយស្ថានទូតចិន ស្ថានទូតវៀតណាម ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មចិនប្រចាំព្រះរាជាណាចក្រកម្ពុជា គម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-បន្តសិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី ប្លង់សាងសង់

របស់ថ្មីខាងមុខព្រឹទ្ធសភា និងជួសជុលសាលបដិសណ្ឋារកិច្ច

-បន្តរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥ របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្ដើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងការបំពាក់សម្ភារៈ

-បន្តតាមដានអាណត្តិជំពូក៦០, ៦១ និង៦២ ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

-បន្តការងារជួសជុលថែទាំអគារ ជួសជុលអគារក្រហម និងជួសជុលផ្លាស់ប្ដូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

-តាមដានការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

-បន្តកសាងសេចក្ដីព្រាងផែនការបណ្ដុះបណ្ដាលឆ្នាំ (២០២៣-២០២៥)

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**III-សេចក្ដីសន្និដ្ឋាន**

ក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារផ្តល់សេវាលើមុខងារទាំង៥ សម្រេចបានលទ្ធផលល្អ។ ដោយស្ថិតក្នុងបរិបទនៃដំណើរឆ្ពោះទៅការបោះឆ្នោតសកល នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ និងដំណើរឆ្ពោះទៅមូលដ្ឋានរបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ក្នុងអំឡុងពេលវិស្សមកាល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្តោតការយកចិត្តទុកដាក់ ជាអាទិភាព លើការផ្តល់សេវាគាំទ្រលើមុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

ព្រឹទ្ធសភាបានចាប់ផ្តើមបើកទំព័រសកម្មភាពឆ្នាំថ្មី២០២៣ ដោយមានសកម្មភាពចម្រុះលើមុខងារទាំង៥ ដែលទាមទារបរិមាណ និងគុណភាពខ្ពស់ជាងមុនៗ

ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសទី៦) ព្រមទាំងបន្តផ្សព្វផ្សាយដល់មន្ត្រីរាជការឱ្យយកចិត្តទុកដាក់អនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។ ♰

ថ្ងៃអង្គារ [illegible] ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

**អគ្គលេខាធិការ**

**អ៊ុំ_សារឹទ្ធ**